# ធនាគារ ព្រីនស៍ ម.ក

## បញ្ញត្តិនិងលក្ខខណ្ឌសម្រាប់កម្មវិធីលើកទឹកចិត្តចំពោះការស្នើសុំបុនហិរញ្ញប្បទានឥណទានគេហដ្ឋានជាមួយធនាគារ ព្រីនស៍

តាមរយៈការស្នើសុំបុនហិរញ្ញប្បទានឥណទានគេហដ្ឋានអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្ត អតិថិជនយល់ព្រមអនុវត្តតាមបញ្ញត្តិ និងលក្ខខណ្ឌដូចខាងក្រោម ("**កម្មវិធីលើកទឹកចិត្ត**") ព្រមទាំងគោលនយោបាយឥណទាន និងគោលនយោបាយ និងនីតិវិធីដែលពាក់ព័ន្ធរបស់ធនាគារ ព្រីនស៍ ម.ក ("**ធនាគារ ព្រីនស៍**")៖

១. រាល់អតិថិជន អាចដាក់ពាក្យសុំបុនហិរញ្ញប្បទានឥណទានគេហដ្ឋានលើកដំបូង ពីគ្រឹះស្ថានហិរញ្ញវត្ថុផ្សេងបានជាមួយនឹងធនាគារ ព្រីនស៍ ("**អតិថិជន**")។

២. ក្នុងករណីពាក្យស្នើសុំបុនហិរញ្ញប្បទានឥណទានគេហដ្ឋានរបស់អតិថិជន ត្រូវបានដាក់ក្នុងអំឡុងរយៈពេលកម្មវិធីលើកទឹកចិត្តនេះ ត្រូវបានអនុម័តយល់ព្រមដោយធនាគារ ព្រីនស៍ ទៅតាមឆន្ទានុសិទ្ធិរបស់ខ្លួន អតិថិជនអាចទទួលបានការផ្តល់ជូននូវអត្ថប្រយោជន៍ស្របតាមបញ្ញត្តិ និងលក្ខខណ្ឌខាងក្រោម៖

| ការផ្តល់ជូន | លក្ខខណ្ឌ | រយៈពេលនៃកម្មវិធីលើកទឹកចិត្ត (ថ្ងៃដាក់ស្នើសុំ) |
|---|---|---|
| **កម្មវិធីលើកទឹកចិត្តចំពោះការស្នើសុំបុនហិរញ្ញប្បទានឥណទានគេហដ្ឋាន** | | |
| - ទំហំឥណទាន៖ រហូតដល់៨០% នៃតម្លៃវាយតម្លៃលើទ្រព្យធានា + បុព្វលាភធានារ៉ាប់រងរហូតដល់ ១០% នៃតម្លៃវាយតម្លៃលើទ្រព្យធានា<br>- រយៈពេលឥណទាន៖ រហូតដល់២៥ ឆ្នាំ<br>- កម្រៃសេវាអនុម័តឥណទាន៖ ០,៥% នៃទំហំឥណទានបានអនុម័ត<br>- ការប្រាក់៖ ៦,៨៨% ក្នុងមួយឆ្នាំ (ឆ្នាំទី ១) និង ៧,៩៩% ក្នុងមួយឆ្នាំ (ចាប់ពីឆ្នាំទី២ទៅ)<br>- កម្រៃសេវាបុនហិរញ្ញប្បទាន៖ លើកលែង | - ជាអតិថិជនកំពុងប្រើប្រាស់ឥណទានគេហដ្ឋានជាមួយនឹងគ្រឹះស្ថានហិរញ្ញវត្ថុផ្សេង ឬបុរី បានយ៉ាងតិច ១២ខែ<br>- រយៈពេលហាមឃាត់ការទូទាត់សងឥណទានដោយផ្នែកឬទាំងស្រុងមុនកាលកំណត់៖ ៥ឆ្នាំ ឬប្រាក់ពិន័យ ៣%នៃទឹកប្រាក់ទូទាត់សងមុនកាលកំណត់<br>- ការជូនដំណឹងការទូទាត់សងមុនកំណត់៖ ៣ខែ ឬប្រាក់ពិន័យ១% នៃទឹកប្រាក់ទូទាត់សងមុនកាលកំណត់<br>- ទ្រព្យធានា៖ ប្លង់រឹង<br>- តម្រូវឲ្យទិញធានារ៉ាប់រងលើការទូទាត់សងឥណទានជាមួយនឹងក្រុមហ៊ុនធានារ៉ាប់រង AIA ប្រភេទ LRI/PureProtection/5PX/25P25 | ០១ កក្កដា ដល់១៥ ធ្នូ ២០២៣ |

| | | |
|---|---|---|
| | - បញ្ញត្តិ និងលក្ខខណ្ឌនៃសំណុំឯកសារហិរញ្ញប្បទាន/ឥណទាននៃ ធនាគារ ព្រីនស៍ ត្រូវអនុវត្ត | |

៣. **ការរក្សាសិទ្ធិ ការរួចផុត និងការកម្រិតនៃការទទួលខុសត្រូវ**

ក. អតិថិជន យល់ព្រមថា ធនាគារ ព្រីនស៍ រួមបញ្ចូលទាំង ម្ចាស់ភាគហ៊ុន អភិបាល ឬបុគ្គលិករបស់ ធនាគារ ព្រីនស៍ មិនត្រូវទទួលខុសត្រូវលើ រាល់ការខូចខាតណាមួយ ទោះដោយផ្ទាល់ ឬដោយប្រយោល ជាពិសេស ឬដោយចៃដន្យ ដែលកើតឡើងទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះឡើយ។

ខ. អតិថិជន យល់ព្រមដោយមិនដកវិញថា អតិថិជនយល់ព្រមសងសំណង និងធានាថា ធនាគារ ព្រីនស៍ នឹងទទួលបានសំណងគ្រប់ពេលណាមួយ លើរាល់ការបាត់បង់ ការខូចខាត កម្រៃសេវា កម្រៃសេវាផ្លូវច្បាប់ និងការចំណាយផ្សេងៗ និងរាល់វិបាកដែលកើតឡើងលើ ធនាគារ ព្រីនស៍ ឬ បានទទួលរងដោយ ធនាគារ ព្រីនស៍ ចំពោះការទាមទារ ឬបណ្តឹងណាមួយដែលធ្វើឡើងដោយ អតិថិជន ឬភាគីទីបី ដែលកើតឡើង ឬទាក់ទងនឹងបញ្ញត្តិដែលមានចែងក្នុងបញ្ញត្តិនិងលក្ខខណ្ឌនេះ។

៤. ក្នុងករណីមានការឆបោក ឬក្លែងបន្លំដែលប្រព្រឹត្តដោយ ឬមានពាក់ព័ន្ធនឹងអតិថិជនទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ អតិថិជនរូបនោះនឹងបាត់បង់សិទ្ធិចូលរួមកម្មវិធីលើកទឹកចិត្តនេះ ដោយរួមទាំងអត្ថប្រយោជន៍ផ្សេងៗដែលខ្លួនទទួលបាន។ អតិថិជន ត្រូវប្រគល់ជូន ធនាគារ ព្រីនស៍ វិញ នូវរាល់អត្ថប្រយោជន៍ដែលខ្លួនបានទទួលពី ធនាគារ ព្រីនស៍ តាមរយៈកម្មវិធីលើកទឹកចិត្តនេះ (ប្រសិនបើមាន) និងត្រូវសងសំណងការខូចខាតផ្សេងៗទៅតាមបញ្ញត្តិច្បាប់ជាធរមាន។

៥. ធនាគារ ព្រីនស៍ រក្សាសិទ្ធិគ្រប់យ៉ាង ក្នុងការធ្វើវិសោធនកម្មលើបញ្ញត្តិនិងលក្ខខណ្ឌនេះ ពន្យាពេល បន្ថែមរយៈពេល ឬលុបចោលកម្មវិធីលើកចិត្តនេះ និង/ឬអត្ថប្រយោជន៍ដែលផ្តល់ជូន នៅពេលណាមួយក្នុងរយៈពេលនៃកម្មវិធីលើកទឹកចិត្ត ដោយមិនមានការទទួលខុសត្រូវ តាមរយៈការជូនដំណឹងពីការផ្លាស់ប្តូរ នៅលើគេហទំព័រផ្លូវការ ឬតាមមធ្យោបាយទំនាក់ទំនងដែលមានផ្សេងទៀតរបស់ ធនាគារ ព្រីនស៍។

៦. បញ្ញត្តិនិងលក្ខខណ្ឌនេះ ត្រូវបានគ្រប់គ្រងដោយច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ រាល់វិវាទដែលកើតឡើង ឬទាក់ទងនឹងកម្មវិធីលើកទឹកចិត្តនេះ នឹងត្រូវបានដោះស្រាយ ដោយអនុលោមតាមគោលនយោបាយដោះស្រាយបណ្តឹងអតិថិជនរបស់ ធនាគារ ព្រីនស៍ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។